# អភិបូជានៅព្រះសហគមន៍សន្តីតេរេសានៃព្រះកុមារយេស៊ូ

## បឹងឈូក ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២២

## "ធ្វើជាអ្នកបម្រើតាមរបៀបព្រះយេស៊ូ"

បងប្អូនជាទីស្រឡាញ់

ថ្ងៃនេះដែលយើងចូលនៅក្នុងរដូវធម្មតា បន្តពីព្រះយេស៊ូបានចាប់កំណើតជាមនុស្ស បន្តពីព្រះយេស៊ូបានណែនាំឱ្យយើងគោរពគ្រួសារដ៏វិសុទ្ធ។ យើងទទួលស្គាល់ថា ពិតមែនព្រះយេស៊ូជាព្រះគ្រីស្ត នៅពេលនោះព្រះយេស៊ូចាប់ផ្តើមបេសកកម្មតែម្តង។ នៅពេលព្រះយេស៊ូចាប់ផ្តើមប្រកាសដំណឹងល្អនៅតាមសន្តយ៉ូហាន ព្រះយេស៊ូមានសញ្ញាសម្គាល់មួយយ៉ាងពិសេស។ គឺណែនាំឱ្យទឹកក្លាយទៅជាស្រាទំពាំងបាយជូរ នៅក្នុងពិធីមង្គលការនៅភូមិកាណា ដើម្បីឱ្យភ្ញៀវទាំងអស់ពោរពេញដោយអំណរសប្បាយ។

នៅពេលយើងឃើញសញ្ញាសម្គាល់នេះ យើងចាប់ផ្តើមយល់ដែរអំពីរបៀបរបស់ព្រះយេស៊ូ គឺព្រះយេស៊ូធ្វើដំណើរជាមួយយើង នៅក្នុងគ្រប់កាលៈទេសៈនៃជីវិតរបស់យើង។ ពេលព្រះយេស៊ូបានជ្រើសរើសមង្គលការ ដើម្បីបង្ហាញសម្គាល់ទី១របស់ព្រះអង្គ គឺជាពេលវេលាមួយសំខាន់ណាស់សម្រាប់គ្រួសារនីមួយៗ។ អាពាហ៍ពិពាហ៍ ជាពេលវេលាដែលយើងពោរពេញដោយអំណរសប្បាយ យើងបានត្រៀមពីយូរ អញ្ជើញភ្ញៀវដើម្បីចូលរួមពិធីជប់លៀង ប្តីប្រពន្ធថ្មីពោរពេញដោយអំណរសប្បាយដោយបង្កើតគ្រួសារថ្មី។ ឪពុកម្តាយ លោកតាលោកយាយ បងប្អូនបានរៀបចំខ្លួនស្អាតដើម្បីចូលរួម ណែនាំឱ្យគ្រួសារទាំងអស់មានសេចក្តីសុខ។

យើងបានឃើញនៅក្នុងពេលវេលាកូវីដ-១៩ គេបានបិទពិធីរៀបការ នៅពេលនោះមានប៉ុន្មានគូដែលបានរៀបការស្ងាត់ៗ ឬបានធ្វើតែពិធីតូចជាមួយក្រុមគ្រួសារ។ ប៉ុន្តែ អ្វីដែលសំខាន់គឺសម្រាប់ជីវិតជាគ្រួសារនៅពេលយើងចូលនៅក្នុងពិធីមង្គលការ យើងពោរពេញដោយសុភមង្គល។ ព្រះយេស៊ូបានជ្រើសរើសពេលវេលានេះ ដែលជាពេលវេលាសំខាន់បំផុតសម្រាប់គ្រួសារមួយដើម្បី

បង្ហាញអំពីឋានៈរបស់ព្រះអង្គ។ ជាពេលវេលាដែលព្រះយេស៊ូបានបង្ហាញអំពីសិរីរុងរឿងរបស់ព្រះអង្គ នៅក្នុងជីវិតធម្មតានៃក្រុមគ្រួសារ នៅក្នុងពេលវេលាដ៏សំខាន់បំផុត ណែនាំឱ្យយើងយល់ថា ពិតមែនព្រះយេស៊ូនៅជាមួយយើងគ្រប់ពេលវេលា។

ដូច្នេះ នៅក្នុងឆ្នាំ២០២២នេះ សិស្សសាលាចាប់ផ្តើមចូលរៀនវិញហើយ យើងក៏កំពុងភ័យអំពីការរីកចម្រើនរបស់មេរោគបម្លែងខ្លួន(អូមីក្រុង) នៅក្នុងប្រទេសកម្ពុជាយើង។ ប៉ុន្តែ អ្វីក៏ដោយយើងដឹងថាព្រះយេស៊ូគង់នៅជាមួយយើង ព្រះយេស៊ូធ្វើដំណើរជាមួយយើងពីមួយថ្ងៃទៅមួយថ្ងៃ។ យើងនៅកន្លែងណាក៏បាន យើងនៅរោងការក៏បាន យើងនៅសាលាក៏បាន យើងនៅកន្លែងធ្វើការក៏បាន យើងនៅមន្ទីរពេទ្យក៏បាន... យើងដឹងថាព្រះយេស៊ូគង់នៅជាមួយយើង នេះជាអ្វីដែលសំខាន់បំផុត។ ប៉ុន្តែ នៅពេលយើងទទួលស្គាល់ថាព្រះយេស៊ូគង់នៅជាមួយយើង យើងត្រូវការនឹកឃើញដល់ពាក្យរបស់ព្រះនាងម៉ារីដែលមានប្រសាសន៍ថា "**អ្វីៗដែលលោកប្រាប់ឱ្យធ្វើចូរធ្វើទៅ**"។ ណែនាំឱ្យយើងយល់ថា នៅគ្រប់ពេលវេលា នៅក្នុងកាលៈទេសៈទាំងអស់យើងត្រូវការធ្វើជាអ្នកបម្រើ បម្រើដល់បងប្អូនឯទៀតៗ។

យើងដឹងថាព្រះយេស៊ូគង់នៅជាមួយយើង និងតាមរយៈព្រះនាងម៉ារីយើងដឹងថាយើងជាអ្នកបម្រើ។ នៅពេលព្រះនាងម៉ារីបានទទួលដំណឹងថា ធ្វើជាមាតារបស់ព្រះជាម្ចាស់ ភ្លាមព្រះនាងម៉ារីមានចម្លើយថា "**ខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គសូមឱ្យបានសម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គចុះ**"។ នៅក្នុងសញ្ញាសម្គាល់មុនគេបង្អស់ ព្រះនាងម៉ារីដូចជាបានអនុវត្តចម្លើយរបស់ព្រះនាងដែលថា "**ខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គសូមឱ្យបានសម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គចុះ**"។ ព្រះនាងម៉ារីក៏បានណែនាំឱ្យយើងអនុវត្តតាមដែរ ដូចជាព្រះនាងម៉ារីបានផ្ទេរសិទ្ធិដល់យើងយ៉ាងពេញលក្ខណៈឱ្យយើងធ្វើជាអ្នកបម្រើដែរ។ នៅពេលយើងឃើញ យើងលឺព្រះយេស៊ូមានព្រះបន្ទូលណាមួយឱ្យយើងធ្វើតាម។ ពេលយើងឃើញបងប្អូនឯទៀតៗមានសេចក្តីត្រូវការ មានទុក្ខលំបាក មានទុក្ខព្រួយណាមួយ យើងដឹងថានៅក្នុងទុក្ខលំបាក នៅក្នុងអំណរសប្បាយ មានវត្តមានរបស់ព្រះយេស៊ូ ដោយសារព្រះអង្គគង់នៅជាមួយយើងគ្រប់ពេលវេលា។ ហេតុនេះហើយ ណែនាំឱ្យយើងគ្រប់ពេលវេលានៅក្នុងជីវិតរបស់យើង ឱ្យយើងនឹកឃើញថាយើងជាអ្នកបម្រើ អ្នកបម្រើជាមួយព្រះនាងម៉ារី អ្នកបម្រើតាមរបៀបព្រះយេស៊ូ។

នៅក្នុងឆ្នាំ២០២២នេះ ឱ្យយើងយកចិត្តទុកដាក់ទៅជាគ្រីស្តបរិស័ទសកម្ម គ្រីស្តបរិស័ទដែលធ្វើដំណើររួមជាមួយគ្នា គ្រីស្តបរិស័ទដែលចេះបម្រើគ្នាទៅវិញទៅមកនៅក្នុងព្រះសហគមន៍ គ្រីស្ត

បរិស័ទដែលចេះបម្រើបងប្អូនឯទៀតៗនៅក្នុងគ្រប់កាលៈទេសៈ។ យើងដឹងថា យើងជាអ្នកបម្រើ តាមអំណោយទានដែលយើងបានទទួល យើងបានទទួលព្រះវិញ្ញាណតែមួយ យើងបានទទួល ជំនឿតែមួយ យើងមានពិធីជ្រមុជទឹកតែមួយ ប៉ុន្តែយើងជាអ្នកបម្រើព្រះអម្ចាស់តែមួយព្រះអង្គដែរ ។ យើងទាំងអស់គ្នា យើងមានសមត្ថភាពខុសៗគ្នា យើងមានកម្លាំងខុសៗគ្នា ប៉ុន្តែនៅក្នុងស្ថាន ភាពរបស់យើងផ្ទាល់ យើងធ្វើដូចម្តេចដើម្បីទៅជាអ្នកបម្រើសង្គម អ្នកបម្រើបងប្អូនឯទៀតៗ អ្នក បម្រើរបស់ព្រះជាម្ចាស់ដើម្បីឱ្យយើងបង្កើតពិភពថ្មីប្រកបដោយសុខសន្តិភាព។

នៅក្នុងសារលិខិតរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ ក្នុងទិវាអធិដ្ឋាន សម្រាប់សុខសន្តិភាពនៅក្នុងពិភពលោក។ សម្តេចប៉ាប បានអញ្ជើញយើងឱ្យយើងយកចិត្តទុក ដាក់រវាងគ្នានឹងគ្នា ជាពិសេសក្មេងៗជាមួយចាស់ៗ ឱ្យជំនាន់នីមួយៗអាចធ្វើដំណើរជាមួយគ្នា យ៉ាងពិតប្រាកដបាន។ នៅពេលចាស់ៗចេះយល់ចិត្តក្មេងៗ នៅពេលក្មេងៗចេះគោរពស្រឡាញ់ ចាស់ៗ បីដូចជាយើងបានបង្កើតការសន្ទនារវាងក្មេងៗនិងចាស់ៗ ដែលណែនាំឱ្យសង្គមរបស់ យើងពោរពេញដោយសេចក្តីសុខ។ ដោយសារយើងបានទទួលបទពិសោធន៍ ប្រាជ្ញា ពីចាស់ៗ យើងជាក្មេងៗយើងខិតខំស្តាប់អ្វីដែលលោកតាលោកយាយអប់រំដល់យើង ដើម្បីឱ្យយើងទៅជា ពលរដ្ឋល្អ ដើម្បីឱ្យយើងទៅជាគ្រីស្តបរិស័ទដ៏ល្អ។

សម្រាប់ព្រះសហគមន៍របស់យើង ដែលយើងមានលោកយាយលោកតា មានពូមីង មានក្មេងៗ ច្រើន។ អ្វីដែលសំខាន់ឱ្យក្មេងៗនិងយុវជនស្តាប់លោកតាលោកយាយ ដើម្បីទទួលការអប់រំ ដើម្បី យល់អំពីជំនឿពីដើម ដើម្បីយល់អំពីរបៀបដែលយើងត្រូវការគោរពព្រះយេស៊ូ។ ដើម្បីយល់អំពី របៀបដែលយើងគោរពសន្តយ៉ូសែបនិងសន្តីម៉ារី យើងធ្វើដូចម្តេចដើម្បីធ្វើជាគ្រីស្តបរិស័ទសកម្ម នៅក្នុងសង្គម។ យើងជាក្មេងៗ យើងត្រូវតែស្តាប់និងគោរពលោកតាលោកយាយ ដើម្បីយកបទ ពិសោធន៍។ ឱ្យយើងយកចិត្តទុកដាក់ដើម្បីបំពេញតួនាទីរបស់យើងជាយុវជនយុវនារី ជាពូមីង ជា លោកយាយលោកតា តាមព្រះអំណោយទានដែលយើងបានទទួលនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ដូចសន្តប៉ូលបានរំលឹកដល់យើងថា យើងមានអំណោយទានខុសៗគ្នា ប៉ុន្តែឱ្យអំណោយទាននេះ ចេញជាស្នាដៃយ៉ាងល្អ។ ណែនាំឱ្យយើងយល់ថា យើងមានអំណោយទានផ្សេងៗពីគ្នា អំណោយ ទាននេះមិនមែនសម្រាប់យើងផ្ទាល់ ប៉ុន្តែដើម្បីបម្រើ។

ថ្ងៃនេះ តាមរយៈក្រុមចម្រៀងនិងភ្លេង យើងចូលនៅក្នុងអភិបូជាដោយអំណរសប្បាយ ដោយសារយើងបានស្តាប់បទចម្រៀង ទំនុកតម្កើង ណែនាំឱ្យដួងចិត្តរបស់យើងចង់លើកតម្កើង

សិរីរុងរឿងរបស់ព្រះជាម្ចាស់ដូចព្រះនាងម៉ារីដែរ។ ដូច្នេះ យើងត្រូវតែយក និងយល់អំពីស្នាដៃរបស់យើង សមត្ថភាពរបស់យើងនៅក្នុងឆ្នាំ២០២២នេះ ដើម្បីធ្វើដំណើរជាមួយព្រះយេស៊ូដោយដឹងថាព្រះយេស៊ូធ្វើដំណើរជាមួយយើង និងដើម្បីបម្រើបងប្អូនឯទៀតៗ។ ដូចព្រះនាងម៉ារីបានអញ្ជើញយើង ឱ្យយើងធ្វើអ្វីៗទាំងអស់តាមព្រះបន្ទូលរបស់លោក ដើម្បីឱ្យពិភពរបស់យើង សង្គមរបស់យើង ឆ្នាំនេះទោះបីមានអ្វីដែលកើតឡើងយើងដឹងថាយើងជាគ្រីស្តបរិស័ទដែលត្រៀមជានិច្ច ដែលយកចិត្តទុកដាក់ជានិច្ច ដែលស្រឡាញ់ព្រះជាម្ចាស់ជានិច្ច ដែលបម្រើជានិច្ច។ នេះណែនាំឱ្យជីវិតរបស់យើង រកឃើញសេចក្តីសុខនិងអំណរសប្បាយនៅក្នុងគ្រប់កាលៈទេសៈដែលអាចកើតឡើង។

ថ្ងៃនេះ យើងអធិដ្ឋាននិងអរព្រះគុណព្រះជាម្ចាស់ដែលបានចាប់កំណើតជាមនុស្ស អរព្រះគុណព្រះជាម្ចាស់ដែលធ្វើដំណើរជាមួយយើង អរព្រះគុណព្រះជាម្ចាស់ដែលណែនាំឱ្យយើងទៅជាអ្នកបម្រើ ដែលពោរពេញដោយកម្លាំងកាយកម្លាំងចិត្ត ពោរពេញដោយជំនឿរឹងមាំ ពោរពេញដោយសេចក្តីស្រឡាញ់ ដើម្បីឱ្យជីវិតរបស់យើង និងជីវិតរបស់បងប្អូនរីកចម្រើនថែមទៀតនៅក្នុងសុខសន្តិភាព៕

+ លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ
អភិបាលព្រះសហាគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ